**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# របាយការណ៍កិច្ចប្រជុំ
# ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី៥

១. **ថ្ងៃ ខែ ឆ្នាំ៖** ថ្ងៃព្រហស្បតិ៍ ៦កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣

២. **ទីកន្លែង៖** នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាយ(Zoom)

៣. **ប្រធាន និងសមាសភាពចូលរួម ៖**

៣.១ ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

៣.២ សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការពាក់ព័ន្ធ ដែលចូលរួមផ្ទាល់ចំនួន២២ និងតាមប្រព័ន្ធអនឡាយចំនួន៤៣រូប សរុបចំនួន៤៥រូប។

៤. **របៀបវារៈ៖**

៤.១- មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

៤.២- បទបង្ហាញស្តីពី របាយការណ៍វឌ្ឍនភាព ស្តីពីការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅកម្ពុជាឆមាសទី១ ឆ្នាំ២០២៣ ដោយឯកឧត្តមវេជ្ជ. **ទេព ណារុជ** ប្រធាននាយកដ្ឋានផែនការតាមដាន និងវាយតម្លៃ។

៤.៣- មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជំងឺអេដស៍។៚

៥. លទ្ធផល ៖

៥.១ ជាកិច្ចចាប់ផ្តើម **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស បានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៥ ឆ្នាំ២០២៣ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ដំណើរការនៃកិច្ចប្រជុំមាន៖

**ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ បានមានប្រសាសន៍ជូនអង្គប្រជុំឱ្យបានជ្រាបថា កិច្ចប្រជុំថ្ងៃនេះសំខាន់លើយុទ្ធវិធីជំរុញខ្លាំងក្លាការងារបង្ការ ថែទាំ និងព្យាបាលបន្តដល់ក្រុមប្រឈមមុខនឹងការឆ្លងមេរោគអេដស៍នៅព្រះរាជាណាចក្រកម្ពុជា ។

៥.២ កិច្ចប្រជុំនេះបានផ្តោតលើវឌ្ឍនភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ ឆ្លើយតបនឹងសេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០២២ និងទិសដៅបន្ត ។ ជាលទ្ធផលនៃកិច្ចប្រជុំ បង្ហាញឱ្យឃើញថា ៖

- ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ដែលមានសម្តេចតេជោ នាយករដ្ឋមន្ត្រី ជាប្រមុខដ៏ខ្ពង់ខ្ពស់បំផុត និងការខិតខំប្រឹងប្រែងរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងដៃគូពាក់ព័ន្ធ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ ការឆ្លើយតបនឹងមេរោគអេដស៍នៅកម្ពុជា បានសម្រេចនូវគោលដៅជាតិចំនួន២រួចហើយ ក្នុងចំណោមគោលដៅជាតិទាំងបី (៩៥-៩៥-៩៥ ក្នុងឆ្នាំ២០២៥) ដោយសម្រេចបាន៨៦% សម្រាប់គោលដៅទី១ ៩៩% និង ៩៨% សម្រាប់គោលដៅទី២ និងទី៣។
- សង្ខេបស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍ នៅកម្ពុជាឆ្នាំ២០២២នេះ បានបង្ហាញថា៖ តាមការប៉ាន់ប្រមាណតាមបែបវិទ្យាសាស្ត្រ ក្នុងឆ្នាំ២០២៣ មានអ្នកផ្ទុកមេរោគអេដស៍ប្រមាណ ៧៦,០០០នាក់ អ្នកឆ្លងថ្មីប្រមាណជា ១,៤០០នាក់ និងអ្នកស្លាប់ដោយមេរោគអេដស៍ ១,១០០នាក់។ មកដល់ពេលនេះ មានអ្នកផ្ទុកមេរោគអេដស៍ មកទទួលសេវាថែទាំជំងឺអេដស៍ ចំនួន ៦៤,៩៣១នាក់ ។
- នៅក្នុងចំណោមអ្នកឆ្លងថ្មីមាន៨២%ជាក្រុមប្រជាជនគន្លឹះ និងដៃគូរួមភេទរបស់ពួកគេ។ អត្រាប្រេវ៉ាឡង់នៃក្រុមប្រជាជនគន្លឹះ ស្ត្រីបម្រើសេវាកម្សាន្តមាន៤,៩% បុរសរួមភេទជាមួយនឹងបុរស ៤,0% ក្រុមបំប្លែងភេទមាន៩,៦% ដែលអត្រានេះមានកម្រិតខ្ពស់ បើធៀបនឹងអត្រាប្រេវ៉ាឡង់នៃប្រជាជនដែលមានតែ0,៦% ។

កិច្ចប្រជុំក៏បានពិនិត្យនូវសមិទ្ធផលកន្លងមក ធៀបនឹងសេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គលើកទី២ ឆ្នាំ២០២២ ជាលទ្ធផល៖

- សម្រេចបង្កើតបាននូវក្រុមការងារអន្តរក្រសួង និងក្រុមការងារស្នូលតាក់តែងគោលនយោបាយលុបបំបាត់ជំងឺអេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ ។

- បានរៀបចំសេចក្ដីព្រាង គោលនយោបាយលុបបំបាត់ជំងឺអេដស៍ នៅឆ្នាំ២០២៥ និងចីរភាពនៃកម្មវិធីអេដស៍ ឆ្នាំ២០២៣-២០២៨។
- ការជំរុញលើកទឹកចិត្តគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន រាជធានី ខេត្ត រៀបចំផែនការថវិកាឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការគ្រោង និងអនុវត្តថវិកាសម្រាប់រាជធានី ខេត្តទាំង២៥ និងក្រសួង ស្ថាប័ននានា លើផែនការសកម្មភាពឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍។
- ការជំរុញការផ្តល់សេវាបង្ការ ថែទាំ ក៏ដូចជាកាត់បន្ថយការចម្លងមេរោគអេដស៍ ពីមាតាទៅទារក រាជរដ្ឋាភិបាលបានចេញនូវអនុក្រឹត្យ ស្តីពីវិធានការក្នុងការបង្ការនិងគ្រប់គ្រងការចម្លងមេរោគអេដស៍ លេខ២៨០ អនក្រ.បក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២២។
- ក្នុងការពង្រីកវិសាលភាព ការគាំពារសង្គម និងលើកកម្ពស់ការទទួលបានសេវាសុខភាពសង្គម រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចផ្តល់កិច្ចគាំពារសង្គមដល់បុគ្គលិកបំរើការងារសេដ្ឋកិច្ចក្រៅប្រព័ន្ធផ្នែកសេវាកម្សាន្តមនុស្សពេញវ័យ ។
- ដើម្បីសម្រេចបាននូវគោលដៅជាតិទាំងបី រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចបង្កើនថវិការបស់ខ្លួនក្នុងការឆ្លើយតបនឹងមេរោគអេដស៍ជាបន្តបន្ទាប់ ដែលក្នុងនោះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានបង្កើនរហូតដល់ ៧៩% សម្រាប់ឱសថប្រឆាំងមេរោគអេដស៍។

**ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** បានធ្វើការបញ្ជាក់ថា ការប៉ាន់ប្រមាណថាមានអ្នកឆ្លងមេរោគអេដស៍ថ្មី ក្នុងឆ្នាំ២០២២ ដែលមានន័យថា មនុស្សប្រហែល៤នាក់ បានឆ្លងមេរោគអេដស៍ជារៀងរាល់ថ្ងៃ។ ការឆ្លងមេរោគអេដស៍ថ្មីត្រូវបានកាត់បន្ថយចំនួន៩១% ចាប់តាំងពីការរីករាលដាលនៃមេរោគអេដស៍ខ្ពស់បំផុតក្នុងឆ្នាំ១៩៩៦ ប៉ុន្តែល្បឿននៃការធ្លាក់ចុះបាននឹងកំពុងធ្លាក់ចុះ ហើយមានការថយចុះតែ ៣៣% បើធៀបនឹងឆ្នាំ២០១០។ ការប៉ាន់ស្មានមេរោគអេដស៍ថ្មី បានបង្ហាញថា ការកើនឡើងសមាមាត្រនៃការឆ្លងមេរោគអេដស៍ថ្មីគឺស្ថិតក្នុងចំណោមបុរស និងក្មេងប្រុស ពួកគេមានចំនួន ៧៩% នៃការឆ្លងមេរោគអេដស៍ថ្មីទាំងអស់ក្នុងឆ្នាំ២០២២។ តាមចំនួនប្រជាជន៨៣% នៃការឆ្លងមេរោគអេដស៍ថ្មី សរុបគឺស្ថិតក្នុងចំណោមប្រជាជនគន្លឹះ បុរសរួមភេទជាមួយបុរស ស្ត្រីបំប្លែងភេទ អ្នកដែលប្រើប្រាស់និងចាក់ថ្នាំញៀន និងដៃគូផ្លូវភេទរបស់ពួកគេ ។ សមិទ្ធិផលរបស់ប្រទេសកម្ពុជា ត្រូវបានចាត់ទុកជាគំរូ ក្នុងការសម្រេចបានខ្ពស់បំផុតនូវអត្រាទទួលសេវាព្យាបាល និងអត្រាកាត់បន្ថយមេរោគមកកម្រិតទាបបំផុតក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍។ គិតត្រឹមខែធ្នូ ឆ្នាំ២០២២ អ្នកផ្ទុកមេរោគអេដស៍ ៦៤.៩៣១នាក់ បានកំពុងទទួលបានការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ហើយវាប្រែថា៩៩% នៃអ្នកផ្ទុកមេរោគអេដស៍ ដែលដឹងពីស្ថានភាពរបស់ពួកគេ កំពុងទទួលបានការព្យាបាល ហើយ៩៨% នៃអ្នកផ្ទុកមេរោគអេដស៍ លើការព្យាបាលត្រូវបានកាត់បន្ថយមេរោគមកកម្រិតទាបបំផុត។

នាឱកាសនោះ **ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការប្រធានអង្គប្រជុំបានបញ្ជាក់ថា នឹងទទួលយកនូវសំណើនៅក្នុងកិច្ចប្រជុំដែលបានលើកឡើង៖

១. កែតម្រូវបន្ថែមនូវជាតុចូលមួយចំនួនទាក់ទងនឹងសេចក្តីព្រាងរបាយការណ៍ ឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងចំគោលដៅ ព្រមទាំងឧបសគ្គដែលត្រូវដោះស្រាយ និងលើកសំណើជូនថ្នាក់ដឹកនាំនៅក្នុងកិច្ចប្រជុំពេញអង្គនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ខាងមុខ។

២. សុំ ឯកឧត្តម លោកជំទាវ លោក លោកស្រី តាមក្រសួង ស្ថាប័ន ខេត្ត ជួយផ្តល់របាយការណ៍មកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឱ្យបានទាន់ពេលវេលា។

៣. សុំ រាជធានី ខេត្ត ដែលបានទទួលថវិកាសម្រាប់ការងារប្រយុទ្ធនឹងជំងឺអេដស៍ អនុវត្តសកម្មភាពបានប៉ុន្មានសូមផ្តល់ព័ត៌មានត្រឡប់មកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ឱ្យបានច្បាស់លាស់។ ចំពោះបញ្ហាដែលជាឧបសគ្គក្នុងការអនុវត្ត យើងនឹងលើកឡើងក្នុងកិច្ចប្រជុំបន្ថែមទៀត ដើម្បីស្នើសុំថ្នាក់ដឹកនាំពីអនុសាសន៍ ឬវិធានការជាក់ស្តែង ដើម្បីឆ្លើយតបក្នុងការងារប្រយុទ្ធនឹងជំងឺអេដស៍។

៤.សូមអញ្ជើញសមាជិកក្រុមប្រឹក្សាបច្ចេកទេស ចូលរួមប្រជុំពេញអង្គនៅទីស្តីការគណៈរដ្ឋមន្ត្រីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣។

ចុងបញ្ចប់ **ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ ប្រធានអង្គប្រជុំក៏បានបន្ថែមថា ការងារប្រយុទ្ធនឹងមេរោគអេដស៍ នៅមានរយៈពេលយូរទៅមុខទៀត ដែលតម្រូវឱ្យយើងបន្តធ្វើការរួមគ្នា រវាងអ្នកធ្វើគោលនយោបាយ និងយុទ្ធសាស្ត្រ អ្នកផ្តល់សេវា និងអ្នករងផលប៉ះពាល់។ម្យ៉ាងទៀតត្រូវពង្រឹងភាពជាម្ចាស់ ចាំបាច់ត្រូវមានការផ្លាស់ប្តូរ ដើម្បីពិនិត្យលទ្ធភាពបង្កើនការផ្តល់ថវិកាជាតិ ដោយឡែកដល់ថ្នាក់ក្រោមជាតិ ដែលរួមមានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការ ប្រយុទ្ធនឹងជំងឺអេដស៍ឃុំ សង្កាត់ ដើម្បីបង្កើនបទអន្តរាគមន៍ឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ឱ្យចំលើការងារជាអាទិភាព ពិសេសក្រុមប្រឈមមុខខ្ពស់ និងទីតាំងអាទិភាពដែលមានការចម្លងច្រើនដោយប្រើអន្តរាគមន៍ដែលមានប្រសិទ្ធភាពខ្ពស់ និងជាបណ្តើរៗជានាថីរភាព និងមានភាពធន់នៃប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍៕

ថ្ងៃសុក្រ ៧កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣

**បានពិនិត្យត្រឹមត្រូវ** អ្នកធ្វើរបាយការណ៍

**ក. ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន**

**ប្រធានអង្គប្រជុំ**

សាយ.បុញ្ញ

**ស៊ុំ ផល្លា**

**បណ្ឌិត ឈឹម មិនដារ៉េត**